**សលាកប័ត្រព័ត៌មាន** ៖ កម្រងឯកសារសេរីភាពមូលដ្ឋាន ៖ សេរីភាពរួចផុតពីអំពើរើសអើង ៖ អ្នកស្រឡាញ់ភេទដូចគ្នា

**សេរីភាពមូលដ្ឋាន** ៖ សេរីភាពរួចផុតពីអំពើរើសអើង

**រូបភាពរួម** ៖ ខណៈពេលដែលព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា") មិនទាន់បានអនុម័តច្បាប់ប្រឆាំងនឹងអំពើរើសអើង សេរីភាពរួចផុតពីអំពើរើសអើងត្រូវបានការពារតាមរយៈច្បាប់ជាតិ និងអន្តរជាតិ ។ ទោះបីជាយ៉ាងណាក៏ដោយ ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ មិនត្រូវបានការពារជាពិសេសនោះឡើយ ហើយជាក់ស្តែង ពួកគេកំពុងប្រឈមនឹងអំពើរើសអើង ។ ជាលទ្ធផល ពួកគេត្រូវបានគេបោះបង់ ដែលនេះបង្កជារបាំងរាំងពួកគេមិនឲ្យចូលរួមក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម ក្នុងប្រទេស ។

## សេចក្តីផ្តើម

ដើម្បីអបអរសាទរទិវាមោទនភាពអន្តរជាតិឆ្នាំ២០១២ នៅសប្តាហ៍នេះ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") សូមផ្តោតលើអំពើរើសអើងក្នុងបរិបទអ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទនៅកម្ពុជា ។ សេរីភាពរួចផុតពីការរើសអើងគឺជាសិទ្ធិមូលដ្ឋាន ដែលអនុញ្ញាតឲ្យប្រជាពលរដ្ឋគ្រប់រូបបង្ហាញពីខ្លួនឯង និងរស់នៅដោយគ្មានការភ័យខ្លាច គ្មានអំពើហិង្សា និងគ្មានការបំពានសិទ្ធិ ។ សលាកប័ត្រព័ត៌មាននេះ បង្ហាញអំពីកម្រិតដែលសេរីភាពរួចផុតពីអំពើរើសអើង ត្រូវបានការពារតាមរយៈច្បាប់ជាតិ និងអន្តរជាតិ ចង្អុលបង្ហាញស្ថានភាពជាក់ស្តែងនៃអំពើរើសអើងមកលើ អ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ និងផ្តល់អនុសាសន៍ថាតើយើងអាចបន្តប្រឆាំងនឹងអំពើរើសអើងបានដោយវិធីណា ។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) គឺជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅប្រទេសកម្ពុជា ។

## សេរីភាពរួចផុតពីអំពើរើសអើង – ច្បាប់ជាតិ និងអន្តរជាតិ

សិទ្ធិទទួលបានសេរីភាពរួចផុតពីអំពើរើសអើងត្រូវបានការពារតាមរយៈច្បាប់របស់ប្រទេសកម្ពុជា ។ មាត្រា៣១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") បានចែងថា "*ប្រជាពលរដ្ឋខ្មែរគ្រប់រូប មានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។*" ប្រជាពលរដ្ឋដែលមានសម្លេងភាគតិច ដូចជាជនជាតិភាគតិចជាដើម ត្រូវបានរាប់បញ្ចូលក្នុងរដ្ឋធម្មនុញ្ញ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ សិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទមិនបានការពារដោយជាក់លាក់ឡើយ ។

មាត្រា៣១ នៃរដ្ឋធម្មនុញ្ញបានចែងថា ប្រទេសកម្ពុជាទទួលស្គាល់ និងគោរពសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ("ស.ប.ស.ស") និងកតិកាសញ្ញា និងអនុសញ្ញាពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ហើយបានបញ្ចូល ស.ប.ស.ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធនយោបាយ ("ក.អ.ស.ព.ន") ក្នុងច្បាប់ជាតិ ។ មាត្រា២ នៃស.ប.ស.ស និងក.អ.ស.ព.ន ផ្តល់សកលភាពដល់សិទ្ធិ "ដោយគ្មានការបែងចែកណាមួយឡើយ" មុននឹងផ្តល់ឧទាហរណ៍ជាក់លាក់ដែលបង្ហាញថាសិទ្ធិស្មើគ្នាមិនត្រូវបានបដិសេធឡើយ ។ ប្រទេសកម្ពុជាបានធ្វើសច្ចាប័នលើ ក.អ.ស.ព.ន នៅឆ្នាំ១៩៩២ ។ លើសពីនេះទៅទៀត មាត្រា២៦ នៃក.អ.ស.ព.ន ចែងពីសិទ្ធិការពារពីច្បាប់ស្មើគ្នា ដោយឥតរើសអើង ខណៈដែលមាត្រា៧ នៃស.ប.ស.ស បានបញ្ជាក់ច្បាស់អំពីសិទ្ធិទទួលបានការការពារដោយឥតរើសអើង (ទោះបីជាមិនបានផ្តល់មូលដ្ឋានលម្អិតក៏ដោយ) ។ ដូចនៅក្នុងរដ្ឋធម្មនុញ្ញ និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ មិនត្រូវបានគេរាប់បញ្ចូលក្នុងបញ្ជីមូលដ្ឋាននៃការរើសអើងដែលអាចមាននោះឡើយ ដែលក្នុងនោះ ការការពារអ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទមានត្រឹមតែក្នុងវាក្យស័ព្ទមិនជាក់លាក់គឺ "ស្ថានភាពដទៃទៀត" តែប៉ុណ្ណោះ ។

## ភាពជាក់ស្តែងនៃអំពើរើសអើងប្រឆាំងនឹងអ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ

សង្គមកម្ពុជា ដែលមានរចនាសម្ព័ន្ធ ប្រពៃណី លក្ខណៈវប្បធម៌ និងអត្តចរិតសង្គមបែបបិតាធិបតេយ្យ បានធ្វើឲ្យអ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទត្រូវគេចាត់ទុកថាជាមនុស្សអន់ ឋានៈទាបក្នុងសង្គម ឬត្រូវស្ថិតក្រោមបង្គាប់ ដែលនេះបង្ហាញពីការរើសអើង និងការផាត់អ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទចេញពីសហគមន៍ និងសង្គម ។ អ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទប្រឈមនឹង (១) ការរើសអើងពីក្រុមគ្រួសារដែលភ័យខ្លាចថានឹងទទួលភាពអាម៉ាស់ក្នុងសង្គម ប្រសិនបើពួកគេបង្ហាញអត្តសញ្ញាណរបស់ខ្លួន (២) ការគំរាមកំហែងនៅសាលារៀន និងកន្លែងធ្វើការ (៣) ការរើសអើងពីនិយោជក ទាក់ទងនឹងការងារ ឬឱកាសផ្សេងទៀត (៤) ឧក្រិដ្ឋកម្មដោយការស្អប់ខ្ពើម រួមទាំងការវាយប្រហារដោយហិង្សា និង (៥) ការចាប់ខ្លួន និងបំពានពីសំណាក់ស្ថាប័នអនុវត្តច្បាប់ ដូចជានគរបាលជាដើម ។ ជាងនេះទៅទៀត ការប្រើប្រាស់មិនត្រឹមត្រូវនូវគោលនយោបាយមិនជាក់លាក់ ដូចជាគោលនយោបាយភូមិឃុំមានសុវត្ថិភាពនៅឆ្នាំ២០១០ ត្រូវបានគេរាយការណ៍ថា បានបង្កើនការរើសអើងប្រឆាំងនឹងអ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ ក្នុងតំបន់មួយចំនួនក្នុងប្រទេស ជាពិសេសនៅទីប្រជុំជន និងទីក្រុង ដែលអ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នក

ប្តូរភេទត្រូវបានបំពានដោយប៉ូលីស ឲ្យចាកចេញពីទីកន្លែងជួបជុំគ្នាក្នុងសង្គមដូចជាសួនច្បារ និងថែមទាំងត្រូវបានចាប់ខ្លួនរហូតទាល់តែពួកគេបង់ប្រាក់សំណូកដើម្បីសុំការដោះលែង ។ ជារឿយៗ អ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទជាច្រើន ដែលត្រូវបានគេបដិសេធមិនផ្តល់ការងារឲ្យធ្វើ ត្រូវបង្ខំខ្លួនរកស៊ីផ្លូវភេទដែលខ្លួនមិនពេញចិត្ត ជាពិសេសនៅពេលដែលពួកគេត្រូវមិត្តភក្តិ និងក្រុមគ្រួសារផ្តាច់ចេញ និងមិនមានការគាំទ្រពីសំណាក់អ្នកដទៃ ។ ទោះបីជាចលនាអ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទក្នុងប្រទេសកម្ពុជាកំពុងវិវឌ្ឍន៍ទៅមុខ ដោយបានពង្រីកបណ្តាញ និងទាក់ទាញឲ្យមានការចាប់អារម្មណ៍ជាវិជ្ជមាន ពីសាធារណជនកាន់តែច្រើនក៏ដោយ ក៏នៅមានចំនុចជាច្រើនទៀតដែលយើងត្រូវធ្វើ មុននឹងយើងអាចនិយាយបានថាអ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ ត្រូវបានផ្តល់ភាពស្មើគ្នា និងមានលទ្ធភាពដូចគ្នាក្នុងការប្រើប្រាស់សិទ្ធិរបស់ពួកគេ ។

## ដំណោះស្រាយ ៖ ច្បាប់ប្រឆាំងនឹងអំពើរើសអើង

ការចាប់ផ្តើមដ៏ល្អមួយ ដើម្បីធានាសមភាពចំពោះអ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ អាចធ្វើទៅបានដោយធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ក៏ដូចជាការទទួលស្គាល់និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ថាជាមូលដ្ឋាននៃអំពើរើសអើង ហើយព្រមទាំងទទួលស្គាល់អ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ ដោយបើកចំហដូចអ្នកដែលមានសម្លេងភាគតិចដទៃទៀតដែលត្រូវគេរើសអើង ។ កម្ពុជាក៏ត្រូវតម្រូវឲ្យមានច្បាប់ជាក់លាក់ ដែលប្រឆាំងនឹងអំពើរើសអើងទូទៅ ឧទាហរណ៍ ច្បាប់ប្រឆាំងនឹងអំពើរើសអើង ដែល (១) ទទួលស្គាល់អ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ ក៏ដូចជាក្រុមដែលមានសម្លេងភាគតិច ដោយបើកចំហ ថាជាគោលដៅនៃការរើសអើង (២) ចែងឡើងវិញនូវសិទ្ធិរបស់ពួកគេក្នុងការទទួលបានសមភាព និងការការពារពីអំពើរើសអើង ក្នុងរដ្ឋធម្មនុញ្ញ ស.ប.ស.ស និង ក.អ.ស.ព.ន និង (៣) ដាក់ទោសព្រហ្មទណ្ឌដល់បុគ្គល ក្រុមហ៊ុន ឬស្ថាប័នសាធារណៈ ដែលបន្តគោលនយោបាយរើសអើង ឬសកម្មភាពប្រឆាំងនឹងអ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ ។ ប្រទេសកម្ពុជាក៏គួរតែបញ្ចូលគោលការណ៍យ៉កយ៉ាកាតា (គោលការណ៍នៃការអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិ ស្តីពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ) ក្នុងច្បាប់កម្ពុជា ។ ជាងនេះទៅទៀត យោងតាម<u>សលាកប័ត្រព័ត៌មាន</u>របស់ម.ស.ម.ក ចេញផ្សាយខែមករា ឆ្នាំ២០១២ គោលនយោបាយភូមិឃុំមានសុវត្ថិភាព គួរយកមកពិចារណាឡើងវិញ និងត្រូវមានច្បាប់ដែលត្រឹមត្រូវ និងប្រកបដោយតម្លាភាព ដែលអនុម័តដោយសភាជាតិ ដើម្បីធានាថាសិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជា រួមទាំងអ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ ត្រូវបានការពារដោយត្រឹមត្រូវ ។

ជាចុងក្រោយ សេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សរបស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ("អាស៊ាន") (ស.ប.ស.អ) ដែលជាច្បាប់តំបន់ប្រកបដោយប្រសិទ្ធិភាព នឹងត្រូវធ្វើសច្ចាប័ននៅខែវិច្ឆិកា ឆ្នាំ២០១២ ។ ក្នុងតួនាទីជាប្រធានអាស៊ាន ប្រទេសកម្ពុជាមានតួនាទីយ៉ាងសំខាន់ក្នុងការធ្វើអាទិភាពកម្ម និងតស៊ូមតិដើម្បីឲ្យមានការបញ្ចូលវាក្យស័ព្ទ ដើម្បីការពារអ្នកដែលមានសម្លេងភាគតិច ដែលប្រឈមនឹងអំពើរើសអើង រួមទាំងអ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទផងដែរ ។ សមាជិកអាស៊ានមួយចំនួនបានជំរុញឲ្យមានការការពារដូច្នេះ ប៉ុន្តែសមាជិកដែលមានគំនិតអភិរក្សបានធ្វើការប្រឆាំងយ៉ាងខ្លាំងក្លា ។ ប្រទេសកម្ពុជាគួរធ្វើជាអ្នកដឹកនាំក្នុងបញ្ហានេះ និងកំណត់គោលបំណងក្នុងការស្វែងរកដំណោះស្រាយ ដែលអាចជាការសម្រុះសម្រួលរវាងការកកើតឡើងរបស់អាស៊ានដើម្បីលើកកម្ពស់បញ្ហាទាក់ទងនឹងអ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ ដែលជាបញ្ហាដែលប្រទេសជួបបញ្ហានិន្នាការភេទ និង/ឬអត្តសញ្ញាណយេនឌ័រដូចដែលបានរៀបរាប់ព្រួយបារម្ភជាទីបំផុត និងទទួលស្គាល់ថា អ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ មាននៅទូទាំងអាស៊ាន ហើយពួកគេត្រូវទទួលបានសមភាព និងមានអារម្មណ៍ថាមានសុវត្ថិភាព និងសេរីភាពរួចផុតពីអំពើរើសអើង អំពើហិង្សា និងការបំពានសិទ្ធិ ។

## សេចក្តីសន្និដ្ឋាន

អំពើរើសអើងប្រឆាំងនឹងអ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទនៅប្រទេសកម្ពុជា មិនមានស្ថានភាពអាក្រក់ដូចពីមុនទេ ហើយក៏មិនអាក្រក់ដូចប្រទេសផ្សេងទៀតលើពិភពលោកដែរ ។ ប៉ុន្តែ ផ្លូវដែលយើងត្រូវដើរនៅវែងឆ្ងាយ ហើយរាជរដ្ឋាភិបាលកម្ពុជាអាចសម្រេចបានកិច្ចការច្រើនជាងនេះទៀត ដើម្បីពន្លឿនដំណើរការនេះ ជាពិសេសកំណត់គោលនយោបាយជាក់លាក់ ចំពោះបញ្ហាពាក់ព័ន្ធនឹងអ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ ។ ទោះបីជាការអនុវត្តន៍តាមអនុសាសន៍ខាងលើនឹងមិនអាចដោះស្រាយបញ្ហារើសអើងចំពោះអ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ ដោយស្វ័យប្រវត្តិក៏ដោយ អនុសាសន៍នេះអាចកំណត់ឧទាហរណ៍ដ៏ល្អមួយសម្រាប់ប្រទេស និងតំបន់ ដើម្បីជាផលប្រយោជន៍ដល់អ្នកទាំងឡាយដែលពាក់ព័ន្ធ ។

**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង លោក ហែម សុខលី តាមទូរស័ព្ទ (+៨៥៥ (0) ៩២ ៨0 ៥៨ 0៨) ឬអ៊ីម៉ែល** soklyhem@cchrcambodia.org **ឬ លោក រ៉ូបឺត ហ្វីនជ៍ (+៨៥៥ (0) ៧៨ ៨0 ៩៩ ៦0) ឬអ៊ីម៉ែល** robert.finch@cchrcambodia.org

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

cc BY NC SA